# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០១៣

នៅក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មពាក់ព័ន្ធនឹងដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គរបស់ព្រឹទ្ធសភា ដើម្បីពិនិត្យ និងឲ្យ យោបល់លើសេចក្តីព្រាងច្បាប់នានា ការរៀបចំសិក្ខាសាលា ការបណ្តុះបណ្តាលធនធានមនុស្ស ការរៀបចំឯកសារប្រវត្តិនៃអគារក្នុងព្រឹទ្ធសភា និងបញ្ហាផ្សេងៗទៀត ។ អគ្គលេខាធិការដ្ឋាន បន្តការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កសាងគោលនយោបាយសង្គមកិច្ច ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០២លើក បានរៀបចំសិក្ខាសាលា ស្តីពី ពត៌មានវិទ្យាថ្មី Cloud System និងប្រព័ន្ធIT នៅកម្ពុជា ព្រមទាំងប្រជុំពិភាក្សាការងារជាមួយឯកឧត្តមអគ្គនាយក អគ្គនាយករង ប្រជុំពិនិត្យសេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ប្រជុំកំណែទម្រង់រចនាសម្ព័ន្ធ ប្រជុំគណៈកម្មការរៀបចំថវិកា បន្តជម្រុញការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន៤៤៧ច្បាប់ ។

### ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

-បានរៀបចំដំណើរការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០២លើក និងបានពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០២ ។

### ២.សេវាទ្រទ្រង់មុខងារតំណាង៖

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះទៅតាម

បណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន២៩៦លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ចែកប័ណ្ណកម្មសិទ្ធដីធ្លី ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុប ចំនួន៧៣លើក ។

-ទទួលពាក្យបណ្តឹង ចំនួន០៦ករណី និងបានធ្វើលិខិតអន្តរាគមន៍ជូនទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយ ព្រមទាំងតម្កល់មិនចាត់ការបានចំនួន០៣ករណី ។

**៣.ការងារអន្តរជាតិ៖**

-រៀបចំទទួលគណៈប្រតិភូធុរកិច្ចចិន ។

-PIC ទទួលបានគំពោងគាំទ្រពីរដ្ឋាភិបាលស្វីស សម្រាប់រយៈពេល១០ឆ្នាំ ។

-រៀបចំបែបបទជូនមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន០៨រូប អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលលើកទី៦ ស្តីពី ភាគហ៊ុនពិភពលោក ( ២០១៣-GOS ) នៅសាធារណរដ្ឋប្រជាមានិតចិន ចូលរួមសិក្ខាសាលា ស្តីពី សមាជិកសភាពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ២០១៣ នៅសាធារណរដ្ឋសិង្ហបុរី និងទស្សនកិច្ចសិក្សាអំពីបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅសភាឡាវ ។

-បន្តសិក្សាគំពោងបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធដល់កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Camserv

-ទំនាក់ទំនងស្ថានទូតវៀតណាមអំពីទស្សនកិច្ចសិក្សានៅសភាវៀតណាម (នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន) និងការបញ្ជូនមន្ត្រី០៦រូប ទៅសិក្សាក្រោយឧត្តមសិក្សា នៅប្រទេសវៀតណាម។ បានទំនាក់ទំនង និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូរអន្តរជាតិ ជាមួយ CIM, Koica,ស្ថានទូត Singapore, India, Brunei, Philippine, បែលហ្សិក ឥណ្ឌូនេស៊ី ម៉ាឡេស៊ី រុស្ស៊ី មីយ៉ាន់ម៉ា ថៃ ឡាវ ដាណឺម៉ាក អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវ៉ែស ដើម្បីសុំអាហារូបករណ៍ ទស្សនកិច្ចសិក្សា និងការផ្តល់អ្នកឯកទេសថ្មី ។

**៤.ទំនាក់ទំនងសាធារណៈ៖**

-បានទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NiDA Honh kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-ទំនាក់ទំនង និងសហការជាមួយការិយាល័យស្ថិតិនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចុះធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនសម្តេច ឯកឧត្តម លោកជំទាវ សមាជិក-សមាជិកាព្រឹទ្ធសភា

និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៥៥៥នាក់ ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន០៣វគ្គ ស្តីពីការប្រើប្រាស់ភាសាខ្មែរតាមក្បួនវេយ្យាករណ៍ឲ្យបានត្រឹមត្រូវ, វគ្គMicrosoft Office Word 2007, វគ្គមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង និងការតបណ្តាញ ។

-អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន៤៤នាក់ ។

+ ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស

-មន្ត្រីចំនួន០៤រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី: Diploma in Communication English ,IT& Networking Skill នៅប្រទេសឥណ្ឌា និងវគ្គវិធីសាស្ត្របង្រៀន និងភាពជាអ្នកគ្រប់គ្រងថ្នាក់រៀននៅប្រទេសចិន

-អាហារូបករណ៍ ថ្នាក់បណ្ឌិត និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន០៩នាក់ ។

**៦.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-បន្តទំនាក់ទំនងជាមួយអ្នកបច្ចេកទេសចិន និងទីប្រឹក្សាពាណិជ្ជកម្មចិនក្នុងការសាងសង់អគារ០៣ខ្នង០៣ជាន់ ការបំពាក់ជណ្តើរយន្ត និងការជម្រុញគម្រោងជំនួយបន្ថែម (សាងសង់អគារបន្ថែម១ខ្នងទៀត, ប្រព័ន្ធលូទឹក, ផ្លូវថ្នល់, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,ការសាងសង់សាលប្រជុំព្រឹទ្ធសភាថ្មី) ។ រៀបចំបង្កប់ខ្សែកាបទូរស័ព្ទ និងខ្សែកាបអគ្គិសនី ប្រព័ន្ធទឹក នៅមុខការដ្ឋានអគារ៣ខ្នង៣ជាន់ និងបានរំដោះទឹកភ្លៀងជនលិចចេញពីបរិវេណព្រឹទ្ធសភា ចំនួន០២លើក និងពិនិត្យកែលម្អប្រព័ន្ធលូទឹក ។

**៧.សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១៤លើក ។

-ថតចម្លងឯកសារ ចំនួន២០០សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៩៥ក្បាល ដោះស្រាយសម្ភារ និងសំណើថវិកា ចំនួន៣០៩សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូន ចំនួន១១៧លើក ។

-បានទទួល និងប្រគល់កៅអីពូកទឹកមាស ចំនួន១៦២គ្រឿង។ បញ្ចូលហ្គាស ជួសជុលម៉ាស៊ីនត្រជាក់ ព្រីនធ័រ ទូរស័ព្ទ បន្ទប់ទឹក បណ្តាញអគ្គិសនី ប្តូរអំពូល ព្រី កុងតាក់ និងដាក់នាឡិកា ចំនួន៩៨គ្រឿង។

-បានជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode,Office ចុះតាមដាន Internet និង Network សរុបចំនួន ៤២គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៦១ប្រធានបទ ។

**II.ទិសដៅការងារខែកក្កដា ឆ្នាំ២០១៣**

១-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ជាមួយគណៈប្រតិភូជាតិ អន្តរជាតិ និងអង្គទូតនានា ។

២-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត។

៣-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស។

៤-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ។

៥-ពង្រឹងការគោរពវិន័យ រក្សាសន្តិសុខ សណ្ដាប់ធ្នាប់នៅក្នុងស្ថាប័នក្នុងរដូវបោះឆ្នោត ។

៦-ការត្រៀមរៀបចំបំពាក់កាប៊ីនភ្លើង ជណ្ដើរយន្ត ប្រព័ន្ធអគ្គិសនី លូទឹក សួនច្បារ នៅក្នុងបរិវេណការដ្ឋាន៣ខ្នង និងក្នុងបរិវេណព្រឹទ្ធសភា។

៧-រៀបចំគម្រោងថវិកាឆ្នាំ២០១៤ របស់ព្រឹទ្ធសភា និងបន្តសិក្សាអំពីការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

៨-បន្តការបណ្ដុះបណ្ដាល និងការរកអាហារូបករណ៍ក្នុង និងក្រៅប្រទេសដល់មន្ត្រី ។

៩-បន្តជម្រុញការដ្ឋានសាងសង់អគារ០៣ខ្នង និងបន្តស្វះស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការ។

១០-ការរៀបចំដេញថ្លៃគម្រោងលទ្ធកម្មជំហានទី២ ។

១១-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងសភាកម្ពុជា ព្រមទាំងបន្តបើកទ្វារទៅខាងក្រៅដើម្បីរកជំនួយ និងការគាំទ្របន្ថែម ។

១២-បន្តពិចារណាអំពីការរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាពជាជំហានដំបូង ។

-បន្តពង្រឹងជំហានអនុវត្តការកែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យកាន់ស៊ីជម្រៅ និងកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានហិរញ្ញវត្ថុ។

១៣-ការគិតគូរដល់ដំណើរការប្រព័ន្ធការងារ មធ្យោបាយ និងធនធានសម្រាប់គ្រប់អង្គភាព ព្រមទាំងជីវភាព សុខុមាលភាព មន្ត្រីរាជការ និងបេឡាសង្គមកិច្ច ។

១៤-សិក្សាអំពីការប្រើប្រាស់ថវិការបស់គ្រប់អង្គភាពចំណុះរចនាសម្ព័ន្ធនយោបាយ។

១៥-បន្តសិក្សាអំពីនីតិវិធីអនុវត្តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងរៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន។

១៦-ត្រៀមចូលរួមបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៥ នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣ ។

## III.សេចក្តីសន្និដ្ឋាន

-ក្នុងខែមិថុនានេះ ជាខែដែលអ្នកនយោបាយជាប់ជំពាក់ច្រើនទៅនឹងការងារបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នីតិកាលទី៥ ។ ដោយឡែកអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំដំណើរការកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងពេញអង្គ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី២ ឆ្នាំ១៩៩៩ នៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តជម្រុញការបណ្តុះបណ្តាលធនធានមនុស្ស និងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ដោយទទួលបានលទ្ធផលល្អ ប្រសើរ ជាពិសេសអំពីការស្វែងរកជំនួយ និងការគាំទ្របន្ថែមពីប្រភពក្នុងក្រៅប្រទេស។

ភ្នំពេញ,ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**